## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ១៣៣ "ឃ"
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០
-សំណុំរឿងព្រហ្មទណ្ឌលេខ៥០៧២
ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ៣៥២៨
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខ៤៤៩៦
ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ៣០ នាទីរសៀល នៅសាលសវនាការទី៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជម្រះ

-លោកចៅក្រម [redacted] ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥០៧២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] **អូន** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើចំការ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នផ្ទះគ្មានលេខ ផ្លូវលំ ភូមិពាវាំង ស្រុកលើកដែក ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អៀន (ស) ម្តាយឈ្មោះ [redacted] លី (រ) នៅលីវ ទោសពីមុនគ្មាន ជានីតិជន ។(ក្នុងឃុំ)

- ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៤៥១ "ឈ" ដឃដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

២-ឈ្មោះ [redacted] **វ៉ាន់ដា** ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ សំណង់ ទីកន្លែងកំណើតភូ[redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នផ្ទះគ្មានលេខ ផ្លូវលំ ភូមិពាវាំង ឃុំពាមវាំង ស្រុកលើកដែក ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ម៉ិច (ស) ម្តាយឈ្មោះ [redacted] លន (រ) នៅលីវ ទោសពីមុន គ្មាន ជានីតិជន (ក្នុងឃុំ) ។

- ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៤៥២ "ឈ" ដឃដ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

-មេធាវីការពារក្តីឱ្យជនជាប់ចោទលោក [redacted]។

ជាប់ចោទពីបទ ៖ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខឡូតិ៍លេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង២៣ និង០០នាទី កម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍រដ្ឋបាលក្បាលកោះ ខណ្ឌច្បារអំពៅ បានល្បាតក្នុងមូលដ្ឋាន ពេលមកដល់ចំណុចមុខដីឡូតិ៍លេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក៏បានឃើញជនជាប់ចោទទាំង០២នាក់ ឈ្មោះ [redacted] **វ៉ាន់ដា** **និងឈ្មោះ** [redacted] **អូន** កំពុងតែជិះម៉ូតូម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ ១BP-៦៦៦០ លេខតួ និងលេខម៉ាស៊ីន

Scanned with CamScanner

៤៧៧៦៨១ ដែលជនសង្ស័យឈ្មោះ [redacted] វ៉ាន់ដា កាន់ជាប់និងដៃខាងឆ្វេង ក៏ធ្វើការឃាត់ខ្លួនជនសង្ស័យទាំង០២នាក់ រួមទាំងវត្ថុតាង បញ្ជូនមកកាន់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ធ្វើការសាកសួរ និងចាត់ការតាមច្បាប់ ។

-បានឃើញ របាយការណ៍សំយោគលេខ ០៨២/០១៩ រ.ប.ក ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៤៩ អ.យ.ឈ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨៧៥ "ឈ" ដង ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] អួន បានឆ្លើយថា ៖ ខ្ញុំមកភ្នំពេញដើម្បីមកទិញថ្នាំញៀនជាមួយឈ្មោះ [redacted] វ៉ាន់ដា ទិញពីគេនៅភ្នំពេញ មិនស្គាល់ឈ្មោះ ខ្ញុំទិញថ្នាំញៀនដើម្បីយកមកប្រើប្រាស់ ខ្ញុំទិញយកមកប្រើប្រាស់ពីព្រោះខ្ញុំចង់សាកមើលឲ្យស្គាល់ ។ ខ្ញុំទិញថ្នាំញៀនចំនួន០៤ កញ្ចប់គឺដើម្បីយកមកប្រើប្រាស់តែប៉ុណ្ណោះ។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា បានឆ្លើយថា ៖ ខ្ញុំមកភ្នំពេញដើម្បីមកលេងស្រុកនៅអ្នកលឿង ហើយក៏ទៅទិញថ្នាំញៀន ។ ខ្ញុំចេះប្រើប្រាស់គ្រឿងញៀនរយៈពេល០៤ខែហើយ ។

-ក្រឡាបញ្ជីអានកំណត់ហេតុកោសលវិច័យ ៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬ អាយ) ជារបស់ឈ្មោះ [redacted] វ៉ាន់ដា ដែលមានកម្រិតភាពសុទ្ធ ៧៤.២០ % (ចិតសិបបួន កណ្តក់សញ្ញា ម្ភៃភាគរយ )នៃទម្ងន់សរុប វាស្ថិតនៅក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែង លម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ សុំតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ។ ស្នើសុំលោកចៅក្រមផ្តន្ទាទោសទៅតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ស្នើសុំឲ្យលោកចៅក្រមមេត្តាបន្ធូរបន្ថយទោសដល់រូបកូនក្តីខ្ញុំបាទ ព្រោះកូនក្តីខ្ញុំបានសារភាពកំហុសរួចហើយ។

## សំដីចុងក្រោយ

-ជនជាប់ចោទឈ្មោះ [redacted] អួន និងឈ្មោះ [redacted] វ៉ាន់ដា ៖ សុំបន្ធូរបន្ថយទោសដល់រូបខ្ញុំផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់កំណត់ហេតុកោសលវិច័យគ្រឿងញៀន

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# សំអាងហេតុ

១.កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៩ នៅចំណុចមុខដីឡូត៍លេខ១ ភូមិជ្រោយអំពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] អូន និងឈ្មោះ [redacted] រ៉ាន់ដា ពិតប្រាកដមែន ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អូន និងឈ្មោះ [redacted] រ៉ាន់ដា បានឆ្លើយថា: ពួកខ្លួនឡើងបានឡើងមកភ្នំពេញដើម្បីមកទិញថ្នាំញៀន យកទៅប្រើប្រាស់ ចំនួន០៤កញ្ចប់ ក្រោយពីទិញរួចហើយក៏យកមកកាន់ក្នុងដៃ ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន។ ដូចនេះផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ គឺបញ្ជាក់ថាមានភាពស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចបញ្ជាក់បានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។

៣.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អូន និងឈ្មោះ [redacted] រ៉ាន់ដា ពិតជាបានប្រព្រឹត្តអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដោយជនជាប់ចោទទាំង០២នាក់បានទិញគ្រឿងញៀនចំនួន០៤កញ្ចប់យកមកទុកប្រើប្រាស់ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង ។ ដូចនេះអំពើរបស់ជនជាប់ចោទចបានបំពានលើគោលការណ៍នីត្យានុកូលភាពរំលោភលើមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.តាមលទ្ធផលកោសលវិច័យថាសំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬមាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៤.២០% នៃទម្ងន់សរុបគឺស្មើនឹង ៧៤.២០% x 0,៨៣ក្រាម = 0,៦១ ក្រាម ។ វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែង លម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ជារបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាន់ដា ។

៥.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាសុំតម្កល់ការចោទប្រកាន់ទុកជាបានការដមែល ។ ស្នើសុំលោកចៅក្រមផ្តន្ទាទោសទៅតាមច្បាប់ ។ គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

៦.មេធាវីការពារក្តីឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំឲ្យលោកចៅក្រមមេត្តាបន្ធូរបន្ថយទោសដល់រូបកូនក្តីខ្ញុំបាទ ព្រោះកូនក្តីខ្ញុំបានសារភាពកំហុសរួចហើយ។ គប្បីតុលាការលើកយកមកពិចារណាតាមច្បាប់ ។

៧.សម្តីចុងក្រោយរបស់ជនជាប់ចោទ សុំបន្ធូរបន្ថយទោស គប្បីតុលាការពិចារណាតាមច្បាប់ ។

៨. -វត្ថុចាប់យករួមមាន:

-ស្រោមសំបុត្រពណ៌ស ដែលមានសរសេរថាក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ សង្ស័យថាមានតម្រុយជាគ្រឿងញៀនទម្ងន់ ០.៨៣ ក្រាម ( សូន្យកណ្តក់សញ្ញាប៉ែតសិបបី) ក្រាម និងកូនថង់ប្លាស្ទិកចំនួន០៤ ដោយមានស្នាមមេដៃជនជាប់ចោទឈ្មោះ [redacted] រ៉ាន់ដា និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ គប្បីត្រូវរឹបអូស និងកំទេចចោល ។

-ម៉ូតូ០១គ្រឿងម៉ាក Honda Dream ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1BP-6660 និងទូរស័ព្ទចំនួន០២គ្រឿងម៉ាក Nokia ចុចពិល ពណ៌ខៀវ ០១ និងពណ៌ខ្មៅ ០១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។



Scanned with CamScanner

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] អូន ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] វ៉ាន់ដា ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខឡូត៍លេខ១ ភូមិជ្រោយអពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៥០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ

ក.ឈ្មោះ [redacted] អូន ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] វ៉ាន់ដា ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់រយៈពេល ០២ ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគាររយៈពេល០១ឆ្នាំ ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខឡូត៍លេខ១ ភូមិជ្រោយអពិល២ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ៥០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យករួមមាន ៖ ១. ស្រោមសំបុត្រពណ៌ស ដែលមានសសេរថាក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ សង្ស័យថាមានតម្រុយជាគ្រឿងញៀនទម្ងន់ ០.៨៣ ក្រាម ( សូន្យកណ្តក់សញ្ញាប៉ែតសិបបី) ក្រាម និងកូនថង់ប្លាស្ទិកចំនួន ០៤ ដោយមានស្នាមមេដៃជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ដា និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរឹបអូស និងកំទេចចោល ។ ម៉ូតូ០១គ្រឿងម៉ាក Honda Dream ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1BP-6660 និងទូរស័ព្ទចំនួន០២គ្រឿង ម៉ាក Nokia ចុចពិល ពណ៌ខៀវ ០១ និងពណ៌ខ្មៅ ០១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងប្រកាស នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៩ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

“បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម”

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]